**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ : ១៧៥៥/២០ ក.អ.ជ

ថ្ងៃសុក្រ ១១រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ក្នុងខែតុលា ឆ្នាំ ២០២០ ព្រះរាជាណាចក្រកម្ពុជាក៏ដូចជាតំបន់មួយចំនួនក្នុងភូមិភាគអាស៊ីអាគ្នេយ៍បានទទួលរងឥទ្ធិពលខ្យល់ព្យុះចំនួន ០៤ ចាប់ពីថ្ងៃទី១៣ ខែតុលា ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ នេះដែលបានបណ្តាលឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រាជធានីខេត្តចំនួន ២០ នៅតំបន់ភាគខាងលិច ជើង និងតំបន់ទំនាបកណ្តាលប្រទេសដែលបានបង្ករមហន្តរាយដល់ផ្ទះសម្បែងលំនៅឋានអ្នកស្រុកចំនួន ១២០ ៤១៨ ខ្នង សម្លាប់មនុស្សអស់ ៤០ នាក់ និងប៉ះពាល់ដល់ប្រជាជនចំនួន ១៣៦ ៤៤២ គ្រួសារ ព្រមទាំង សត្វពាហនៈ និងមនុស្សជាច្រើនបាត់បង់ទីជម្រក។ ចំណែកហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ១ ៦៨៥ គ.ម អណ្តូងទឹក បង្គន់អនាម័យ មណ្ឌលសុខភាពមួយចំនួន ត្រូវបានទឹកជនលិចបណ្តាលឲ្យខូចខាតមួយចំនួនធំ ។

ស្ថិតក្នុងសភាពការចំពោះមុខនេះ ថ្នាក់ដឹកនាំក្រសួង មន្ត្រីជំនាញបានរួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន បានចុះជួយសង្គ្រោះប្រជាជនរងគ្រោះ រកកន្លែងទីទួលសុវត្ថិភាព ធ្វើជម្រកស្នាក់នៅបណ្តោះអាសន្ន ឧបត្ថម្ភស្បៀងអាហារ ទឹកស្អាត ថ្នាំសង្កូវ ជូនប្រជាជនរងគ្រោះ ។ បន្ទាប់ពីទឹកជំនន់ទឹកភ្លៀងបានស្រកចុះ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បានដឹកនាំក្រុមការងារជំនាញដោយផ្ទាល់ចុះពិនិត្យ វាយតម្លៃ ការខូចខាតផ្លូវជនបទ និងចាប់ផ្តើមជួសជុលស្តារឡើងវិញជាបន្ទាន់ដើម្បីបង្កលក្ខណៈឲ្យប្រជាជនអាចធ្វើដំណើរ និងដឹកកសិផលនារដូវចម្រូតនេះទៅកាន់ទីផ្សារបានទាន់ពេលវេលា ។ ចំពោះការងារជំនាញ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនៅតែបន្តសកម្មភាព បន្ទាប់ពីជំនន់ទឹកភ្លៀងបានបញ្ចប់ ។

លទ្ធផលដែលក្រសួងសម្រេចបានប្រចាំខែតុលា ឆ្នាំ២០២០ នេះមានដូចខាងក្រោម៖

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការសកម្មភាពទូទាំងប្រទេសសម្រេចបានប្រមាណជា ៨០% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ គិតមកដល់ចុងខែតុលានេះ ។



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែតុលា ឆ្នាំ ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥១៩ នាក់ (ស្រី ៤១១ នាក់) ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែកញ្ញា គឺមានការកើនឡើងចំនួន ០១ នាក់ ដោយសារការទទួលក្របខណ្ឌចូល។ ក្រសួងបានទទួលលិខិតចូលចំនួន ១៤៣ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៤៩ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៣ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១៤៨ ច្បាប់ ។

### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែតុលា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ១២ ០៦៤ ៣៧៨ ៦៤៤ រៀលស្មើនឹង៨,៤៥% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៣៤ ៣៧២ ៦៧៥ ០០០ រៀលស្មើនឹង ១៩,០៩%នៃច្បាប់ថវិកា ។

### ២.២.៣. ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ចូលរួមកិច្ចប្រជុំស្តីពីក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ និងសូចនាករគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យសម្រាប់តាមដាន និងវាយតម្លៃការអនុវត្ត នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រ ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រង ការវិនិយោគសាធារណៈ ២០១៩-២០២៥ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគ នៅសណ្ឋាគារហ្គោលឌិនស៊ីជី ភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០ រៀបចំដោយអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារភ្នំពេញ
- រៀបចំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍សមិទ្ធកម្មឆមាសទី១ និងត្រីមាសទី៣ និងទិសដៅត្រីមាសទី៤ នៃការអនុវត្តថវិកាឆ្នាំ ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ចូលរួមកិច្ចប្រជុំលើកទី ១៨ នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ប្រារព្ធនៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលនៃអង្គវិបស្សនាគោលនយោបាយអភិវឌ្ឍន៍ជនបទ

ឆ្នាំ២០២១-២០៣០ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សុខ សារាវុឌ្ឍ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ**

- រៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការប្រមូលទិន្នន័យទាំង ០៥ តំបន់សម្រាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- ចូលរួមប្រជុំស្តីពី ផែនការមេផ្លូវជនបទ (Rural Road for Master Plan) ជាមួយជំនាញការកូរ៉េ នៅក្រសួងអភិវឌ្ឍន៍ជនបទ រៀបចំដោយគម្រោង RRIP-III ,
- បានចុះប្រមូលព័ត៌មានទិន្នន័យនៅខេត្តកំពត និងខេត្តបាត់ដំបង
- បានរៀបចំរបាយការណ៍សមិទ្ធិកម្មស្តីពីលទ្ធផលក្នុងអនុវត្តថវិកាកម្មវិធីក្នុងត្រីមាសទី៣ ឆ្នាំ ២០២០
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការចំនួន ០២ គឺ អង្គការ iDE និងអង្គការអភិវឌ្ឍន៍ និងសង្គ្រោះសកលកម្ពុជា CGA
- បានផ្តល់លិខិតគាំទ្របន្តអនុស្សារណៈនៃការយោគយល់គ្នារវាងអង្គការ Johanniter International Assistance ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

**២.២.៦. ការងារអធិការកិច្ច និងសវនកម្ម**

- ធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩-២០២០ នៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ៨៥%
- ការងារស្ថាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ៧៥ %
- ផ្លូវជនបទប្រវែង១ ៦៨៥ គ.ម ត្រូវបានជំនន់ទឹកភ្លៀងជនលិចនៅតាមបណ្តារាជធានី-ខេត្ត ចំនួន ២០ ។ ក្រសួងកំពុងមមាញឹកចុះវាយតម្លៃ និងចាប់ផ្តើមជួសជុលឲ្យដំណើរការឡើងវិញជាបណ្តើរៗហើយ ដើម្បីធានានិរន្តភាពនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន
- គម្រោងការងារជួសជុលបន្ទាន់ កំពុងដំណើរការឯកសារចំនួន ៤៣ គម្រោង សម្រេចលទ្ធផល

គិតជាមធ្យមបាន ៨០% ។

### ២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ

- បានសាងសង់អាងត្រងទឹកភ្លៀង ៤ ម៉ែត្រគូប ចំនួន ៦១ អាង នៅខេត្តប៉ៃលិន និងខេត្តមណ្ឌលគិរី
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ២៤ អណ្តូង នៅខេត្តត្បូងឃ្មុំ និងខេត្តស្ទឹងត្រែង
- បានខួងអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ១៨ អណ្តូង នៅខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង និងខេត្តសៀមរាប
- សាងសង់ប្រព័ន្ធចែកចាយទឹក ចំនួន ០១ កន្លែង នៅខេត្តស្ទឹងត្រែង
- ខួងអណ្តូងស្នប់ ចំនួន ១១ អណ្តូង នៅខេត្តមណ្ឌលគិរី និងខេត្តតាកែវ
- បានស្តារស្រះសហគមន៍ ចំនួន ០១ កន្លែង នៅខេត្តតាកែវ ។

### ២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានផ្តល់ចានបង្គន់តាមផ្ទះឯកជន ចំនួន ៥៥ ខ្នងផ្ទះ នៅខេត្តកែប និងខេត្តស្វាយរៀង
- បានអប់រំអនាម័យប្រជាពលរដ្ឋ ចំនួន ៣៨ នាក់ នៅខេត្តកំពង់ចាម
- បានចុះអប់រំផ្សព្វផ្សាយអនាម័យតាមសហគមន៍ ដោយផ្តោតសំខាន់លើអនាម័យលាងសម្អាតដៃដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីការផ្ទៀងផ្ទាត់ភូមិ ODF នៅខេត្តកំពង់ឆ្នាំង ។

### ២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិនៅ ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តព្រៃវែង និងខេត្តបន្ទាយមានជ័យ
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារនៅខេត្តសៀមរាប
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ចំនួន ១៥ វគ្គ មានសិក្ខាកាម ៤៣៤ នាក់ ស្រី ២១០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបន្តធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

### ២.២.១១. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ២៨៩ នាក់ ស្រី ៣៩ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៦៩២ នាក់ ស្រី ៦៤ នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ០៨ នាក់ ស្រី ០៣ នាក់
- បានរៀបចំសិក្ខាសាលាស្តីពី "ការលើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងអង្គភាពអភិវឌ្ឍន៍ជនបទថ្នាក់ខេត្ត" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ មានសិក្ខាកាមចូលរួមសរុបចំនួន ៥២ នាក់ ស្រីចំនួន ០៤ នាក់

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការដឹកនាំ និងគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ មានសិក្ខាកាមចូលរួមសរុបចំនួន ៤៨ នាក់ ស្រីចំនួន ០៧ នាក់
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១៣ ខេត្ត បានរៀបចំ និងកែសម្រួលឯកសារពាក់ព័ន្ធមួយចំនួន រៀបចំគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២១ ព្រមទាំងបន្តការផ្អាកជាបណ្តោះអាសន្នលើការងារបណ្តុះបណ្តាល ដោយសារការបញ្ហាជំងឺកូវីដ-១៩ ។ ដោយឡែកសម្រាប់មជ្ឈមណ្ឌលមួយចំនួន បានបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាលចំនួន ២៥ វគ្គ មានសិក្ខាកាមសរុប ៥៧៧ នាក់ (ស្រី ៣២៧ នាក់) ក្នុងនោះ ៖
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៧ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៣៥ នាក់ (ស្រី ៦៥ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៨២ នាក់ (ស្រី ៦៤ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១២៥ នាក់ (ស្រី ៥៧ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៥ នាក់ (ស្រី ៣៣ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៣ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៩៥ នាក់ (ស្រី ៧៣ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៣ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៦៥ នាក់ (ស្រី ៣៥ នាក់)។

**២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- គិតត្រឹមថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ២១៣ ៣៥៨ ៨៣៥ រៀល (បួនប៊ីលានពីររយដប់បីលានបីរយហាសិបប្រាំបីពាន់ប្រាំបីរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៧២ ៥៦៥,៦៧ ដុល្លារអាមេរិក (មួយលានចិតសិបពីរពាន់ប្រាំរយហុកសិបប្រាំដុល្លារនិងហុកសិបប្រាំពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២១១ នាក់ នៅភូមិគោលដៅចំនួន ១៩១ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥ ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ចូលរួមកិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពី ការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ (ABS SubTWG) លើកទី២ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការត្រួតពិនិត្យអំពីការចំណាយលើផ្នែកជីវៈចម្រុះ

និងការវាយតម្លៃតម្រូវការហិរញ្ញវត្ថុ នៃគម្រោងគំនិតផ្តួចផ្តើមហិរញ្ញប្បទានជីវៈជម្រុះ (BIO FIN) នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែតុលា ឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ១០ ករណី ក្នុងនោះតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រសួងដោះស្រាយបានចំនួន ០៣ ករណី ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២១ ។

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១. គម្រោងកែលម្អផ្លូវជនបទ ដំហាន ២**

គិតត្រឹមដំណាច់ខែតុលានេះ គម្រោងសម្រេច៖

- បានបញ្ចប់ការសាងសង់ផ្លូវ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុប ៥៦១,៣០ គ.ម
- បានបញ្ចប់ការសាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៨៧,៦៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៨៤,៥៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៨៧,៧៩%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៩២,២៥% ។

**២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងបានទទួលការអនុម័តចំនួន ១ ២៨៤ គម្រោង ប្រវែង ១ ១៤៨ ៤៧៨ ម៉ែត្រ បាន និងកំពុងអនុវត្តចំនួន ៥៤៣ គម្រោង ប្រវែង ៥១០ ៣៦០ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១៧ ក្នុង

នោះបានបញ្ចប់ការងារ ចំនួន ២៥៤ គម្រោង ប្រវែង ២១១ ២៨១ ម៉ែត្រ ។

**២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)**

- រៀបចំឯកសារសម្រាប់អនុវត្តផែនការសកម្មភាពជំហានទី២ ។

**២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា**

- កំពុងដាក់ស្នើថវិកាជំហានទី២ ។

**២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍**

គិតត្រឹមខែតុលានេះ គម្រោងសម្រេចៈ

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្តាល ដោយសម្រេចបាន ១៤,៦៤%
- បានទទួលការឯកភាពពីធនាគារពិភពលោក លើរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃសាងសង់ផ្លូវកញ្ចប់ទី ៣ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប
- បានចេញលិខិតជូនដំណឹងស្តីពីលទ្ធផលនៃការដេញថ្លៃដល់ក្រុមហ៊ុនទាំង ១៣ ដែលបានចូលរួមការដេញថ្លៃកញ្ចប់ទី ៣
- កំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសម្រាប់ការងារ Institutional Strengthening and Capacity Building for Disaster Resiliency of Rural Roads ។

**២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២**

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង ព្រៃវែង កំពត ស្វាយរៀង កំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទ ជំហាន ២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងខែតុលានេះ គម្រោងសម្រេចៈ

- ជីកអណ្តូងបានចំនួន ១៨ អណ្តូង
- តម្លើងស្នប់ ចំនួន ១៣២ ស្នប់
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ៣២,៤៩ % ។

**២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា**

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផលកសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ នៅក្នុងខែតុលានេះគម្រោងសម្រេចៈ

- ទីប្រឹក្សាផ្តល់សេវាបច្ចេកទេស Technical Service Provider (TSP) រួមជាមួយ អន្តរក្រសួង(MAFF, MEF, MRD and MoWRAM) បានចុះផ្សព្វផ្សាយអំពីខ្លឹមសារ គម្រោងដល់ក្រុមគោលដៅនៅតាមមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ចំនួន ១២ ខេត្ត
- បានចូលរួមប្រជុំពិនិត្យបាយការណ៍លទ្ធផលផ្សព្វផ្សាយ ដើម្បីកែលម្អវិធីសាស្ត្រផ្សព្វផ្សាយ សម្រាប់យកទៅអនុវត្តតាមបណ្តាស្រុកគោលដៅក្នុងខេត្តទាំង ១២ បន្តទៀត
- ក្រុមការងារអនុវត្តគម្រោងបានប្រជុំរៀបចំផែនការថវិកាគម្រោងសម្រាប់ឆ្នាំ២០២១ ។

**២.៣.៧. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា**

គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា(CSLEP) ជាគម្រោង ក្រោមហិរញ្ញប្បទានឥណទានសហប្រតិបត្តិការ ពីធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ០៥ ឆ្នាំ (២០២០-២០២៥) ។ គម្រោងមានគោលបំណងស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុង នៅខេត្តគោលដៅចំនួន ០៧ រួមមាន ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ ក្នុងខែតុលានេះគម្រោងសម្រេចបាន ៖

- រៀបចំកិច្ចប្រជុំតាមប្រព័ន្ធ Online ជាមួយអង្គភាពអនុវត្តគម្រោង ដើម្បីណែនាំអំពីព័ត៌មានទូទៅរបស់គម្រោង និងកំណត់ខ្សែផ្លូវ
- រៀបចំកិច្ចប្រជុំស្តីពីការរៀបចំផែនការសកម្មភាពការងារ និងផែនការថវិកាសម្រាប់ឆ្នាំ២០២១
- បានជ្រើសរើសទីប្រឹក្សាផ្នែកសង្គម និងបរិស្ថាន
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងាររបស់ក្រសួងបរិស្ថាន និងតំណាងធនាគារពិភពលោក ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោង
- ចូលរួមចុះសិក្សាវាយតម្លៃបឋមលើផលប៉ះពាល់សង្គមផ្នែកជនជាតិដើមភាគតិច នៅតាមបណ្តាខេត្តគោលដៅ ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ជំនន់ទឹកភ្លៀងបានធ្វើឲ្យរាំងស្ទះការងារសាងសង់ ជុសជួសជុលផ្លូវជនបទ សាងសង់អណ្តូងទឹក សាងសង់បង្គន់អនាម័យ និងបានធ្វើឲ្យផ្លូវជនបទខូចខាតមួយចំនួនធំ
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- ទម្លាប់សង្គមក្នុងការបន្ទោបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ

- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

**៣.២. ទិសដៅតាមអង្គភាព**

- បន្តរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០ របស់ក្រសួងលើជំពូកទី៣ ស្តីពីការដឹកនាំ ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និង ជំពូកទី៤ ស្តីពីការប្រើប្រាស់ធនធានសម្រាប់ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ព្រមទាំងបញ្ចប់ការរៀបចំសូចនាករគន្លឹះកម្មវិធីទាំង៥
- រៀបចំសិក្ខាសាលាសម្រាប់តំបន់ទាំង ៥ ស្តីពី ការស្វែងយល់ការងារអភិវឌ្ឍន៍ជនបទនៅមូលដ្ឋាន លើប្រធានបទ សមិទ្ធផល តម្រូវការ និងប្រសិទ្ធភាព លើការងារអភិវឌ្ឍន៍ជនបទនៅទូទាំងប្រទេស ដែលនឹងប្រព្រឹត្តទៅរយៈពេល ០៣ថ្ងៃ នៅទីស្តីការក្រសួង
- ចុះតាមដានសកម្មភាពអង្គការមិនមែនរដ្ឋាភិបាល
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជំរុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា
- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្តាខេត្ត
- បន្តការងារបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច

- ពង្រឹងការផ្ដល់សេវាជូនប្រជាពលរដ្ឋដូចជាការងារតេណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្ដុះបណ្ដាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

ក្នុងខែតុលា ឆ្នាំ២០២០នេះ តំបន់ជនបទមួយភាគធំ (២០ ខេត្ត) បានទទួលរងព្យុះបោកបក់នាំមកជំនន់ទឹកភ្លៀងដែលបណ្ដាលឲ្យខូចខាត និងប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច និងកសិកម្ម ទាំងនៅតំបន់ជនបទ និងជាយរាជធានីភ្នំពេញផងដែរ ។ តាមស្ថិតិគិតត្រឹមថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២០ កន្លងទៅនេះមានផ្លូវជនបទប្រវែង ១ ៦៨៥ គ.ម សំណង់សិល្បការ្យមួយត្រូវបានខូចខាត ។ ក្រសួងអភិវឌ្ឍន៍ជនបទបានចាត់វិធានការអន្តរាគមន៍តាមមុខសញ្ញាគ្រប់ខេត្តដើម្បីត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពខូចខាត និងចាប់ផ្ដើមជួសជុលផ្លូវជនបទឡើងវិញជាបន្ទាន់ដើម្បីឲ្យប្រជាពលរដ្ឋអាចធ្វើចរាចរណ៍ ដឹកកសិផល និងផលិតផលដទៃទៀតមកកាន់ទីផ្សារ ។ ទោះបីជាមានបញ្ហាទឹកជំនន់មួយភាគនៃប្រទេសក៏ដោយ ក៏សកម្មភាពការងារមួយចំនួននៅដំណើរការដដែល ដូចបានបង្ហាញលទ្ធផលខាងលើ ដើម្បីធានានិរន្តរភាពនៃជីវភាពរស់នៅរបស់ប្រជាជនជនបទដោយសុខសាន្ត ក្នុងសង្គមគ្រួសារជនបទនៃព្រះរាជាណាចក្រកម្ពុជាយើង ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**